**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

-សាលក្រមព្រហ្មទណ្ឌមុនអង្គសេចក្ដី

លេខ: ២២៥ "គ១ក្រ១០"

ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២០

**-សំណុំរឿងព្រហ្មទណ្ឌ**

លេខ: ១០០៨

ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០២០

**-សំណុំរឿងស៊ើបសួរ**

លេខ: ៧១៩

ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០២០

**-សំណុំរឿងជំនុំជម្រះ**

លេខ: ៣០៤៨

ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២០

## សាលក្រមមុនអង្គសេចក្ដី

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០២ និង ៣០ នាទីរសៀល នៅសាលសវនាការទី៩ ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ **ប្រធានក្រុមប្រឹក្សា។**

-លោក [redacted] ក្រមសាលាដំបូងរាជធានីភ្នំពេញ **ចៅក្រមប្រឹក្សា។**

-លោក [redacted] មសាលាដំបូងរាជធានីភ្នំពេញ **ចៅក្រមប្រឹក្សា។**

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ។

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

## មេធាវីការពារឱ្យជនជាប់ចោទ

-លោក [redacted]

ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ ពីន។

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១០០៨ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០២០ ដែលមានពាក្យសុំឱ្យកូនក្ដីនៅក្រៅឃុំ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០២០ របស់មេធាវី ហួង គៀនហាក់។**

ដែលមានជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ ពីន ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ សិស្ស ទីកន្លែងកំណើតនៅ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅ ផ្ទះលេខ ៤៩ អឺ២ហ្សិត ផ្លូវលេខ ១៣ ភូមិទី១១ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ពិសិដ្ឋ "រស់" ម្ដាយឈ្មោះ [redacted] សុខពៅ "រស់" នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ-PJ)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៨៣៣ "ច១" ដ.ឃ.ង ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២០។

ជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុច សួនច្បារមាត់ទន្លេ ផ្លូវព្រះស៊ីសុវត្ថិ ភូមិទី៦ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ១៩ និង ៣០នាទី នៅចំណុចសួនច្បារមាត់ទន្លេ ផ្លូវព្រះស៊ីសុវត្ថិ ភូមិទី៦ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលជនរងគ្រោះជាស្ត្រីបរទេសម្នាក់កំពុងដើរឆ្លងផ្លូវ ដោយកាន់ទូរស័ព្ទម៉ាក អាយហ្វូន អេច (IPHONE X) ពណ៌ ស មួយគ្រឿងនៅនឹងដៃ ស្រាប់តែមានជនជាប់ចោទឈ្មោះ [redacted] វឌ្ឍមុនិន្ទ និងឈ្មោះ [redacted] **សំណាង** បានឃើញ ហើយក៏ជិះម៉ូតូមួយគ្រឿងម៉ាក MSX ពណ៌ក្រហម

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ ពីន បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សូមឱ្យតុលាការមេត្តាដោះលែងខ្លួនឱ្យបាននៅក្រៅឃុំផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

-ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស** បានកើតឡើងនៅចំណុច សួនច្បារមាត់ទន្លេ ផ្លូវព្រះស៊ីសុវត្ថិ ភូមិទី៦ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] វឌ្ឍមុនិន្ទ ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ[redacted] សំណាង ហៅ ពីន ភេទប្រុស អាយុ១៥ឆ្នាំ ប្រាកដមែន។

-តាមពាក្យសុំឱ្យកូនក្តីនៅក្រៅឃុំ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០២០ របស់មេធាវី [redacted] ឃើញថា លោកមេធាវី [redacted] ពិតជាបានស្នើសុំឱ្យកូនក្តីខ្លួនឈ្មោះ [redacted]សំណាង ហៅ ពីន ភេទប្រុស អាយុ១៥ឆ្នាំ បាននៅក្រៅឃុំបណ្តោះអាសន្ន ប្រាកដមែន។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ ពីន ដែលបានឆ្លើយនាពេលសវនាការ ឃើញថា ជនជាប់ចោទរូបនេះ ពិតជាបានស្នើសុំនៅក្រៅឃុំបណ្តោះអាសន្ន ប្រាកដមែន។ ប៉ុន្តែជនជាប់ចោទពុំមានហេតុផលអ្វីផ្សេង ក្រៅពីការអះអាងថា ខ្លួនជាអនីតិជន មានអាយុទើបតែ១៥ឆ្នាំ នោះទេ។

-តាមសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ ឃើញថា ដើម្បីការពារប្រយោជន៍ផ្លូវច្បាប់ដល់អនីតិជនដែលជាកូនក្តីខ្លួន និងមិនមែនជាបទល្មើសជាក់ស្តែងផងនោះ ក្នុងនាមខ្លួនជាមេធាវីការស្នើសុំឱ្យ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិចារណាអំពីការដោះលែងឱ្យកូនក្តីខ្លួននៅក្រៅឃុំបណ្តោះអាសន្ន។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងថា: សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

**តុលាការយល់ឃើញថា៖**

-ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ ពីន ត្រូវបានចោទប្រកាន់ពីបទល្មើសឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។

-ដើម្បីធានារក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

-ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈកុំអោយមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

-បទល្មើសគឺបង្កភាពអសន្តិសុខយ៉ាងខ្លាំងដល់សង្គម។

## ហេតុដូច្នេះសម្រេច

**១**-មិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលើជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ ពីន ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្ស ទីកន្លែងកំណើតនៅ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ



Scanned with CamScanner